# និយមន័យនៃអំពើជួញដូរមនុស្ស

## ធាតុសត្យានុមត្ត

ការជ្រើសរើស ឬ ការដឹកជញ្ជូន ឬ ការផ្ទេរ ឬ ការផ្តល់កន្លែងលាក់ខ្លួន ឬ ការទទួលយកមនុស្ស

ដោយមធ្យោបាយគំរាមកំហែងឬការប្រើកំលាំងឬការបង្ខិតបង្ខំតាមរូបភាព ផ្សេងៗ ដូចជាការចាប់ពង្រត់ ការក្លែងបន្លំការបោកបញ្ឆោតការរំលោភលើអំណាចឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកំរៃផ្សេងៗដើម្បីឱ្យមានការយល់ ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ។

ក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម ( ពេស្យាចារលើអ្នកដទៃឬការធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬ សេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈ ស្រដៀងគ្នាទៅនឹងទាសភាពភាពជាអ្នកបំរើដាច់ថ្លៃឬការលក់ដូរសេរីរាង្គជាដើម ។)

## ធាតុអត្តនោមត្ត

***ជនល្មើសមានឆន្ទះ***ក្នុងការជ្រើសរើសការដឹកជញ្ជូនការផ្ទេរការផ្តល់កន្លែងលាក់ខ្លួនឬការទទួលយកមនុស្សក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម ។

ការយល់ព្រមរបស់ជនរងគ្រោះ មិនមានការពាក់ព័ន្ធ

***ភាពខុសគ្នារវាងអំពើរត់ពន្ធមនុស្សនិងការជួញដូរមនុស្ស***

**រត់ពន្ធមនុស្ស**

អ្នកធ្វើទេសន្តប្រវេស្តន៏ ស្ម័គ្រចិត្ត ឱ្យគេរត់ពន្ធខ្លួន

ការរត់ពន្ធមនុស្សចប់នៅពេលទៅដល់ប្រទេសគោលដៅ

ការរត់ពន្ធមនុស្សជានិច្ចកាលឆ្លងដែន

អ្នករងគ្រោះគឺជាប្រទេសគោលដៅ

**ជួញដូរមនុស្ស**

អ្នកដែលត្រូវគេជួញដូរ មិនស្ម័គ្រចិត្ត ឱ្យគេជួញដូរខ្លួន

ជនដែលគេជួញដូរទៅដល់គោលដៅហើយ ត្រូវគេបន្តកេងប្រវ័ញ្ចតទៅទៀត

ការជួញដូរមនុស្សជួនកាលឆ្លងដែន ឬ ជួនកាលប្រព្រឹត្តឡើងក្នុងស្រុក

អ្នករងគ្រោះគឺជាអ្នកដែលត្រូវគេជួញដូរ

## និយមន័យនៃអនីតិជន

អនីតិជននៅក្នុងច្បាប់នេះមានន័យថា ជាជនដែលមានអាយុក្រោម១៨ឆ្នាំ

ជនណាដែលរក្សាទុកអនីតិជនឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួននឹងត្រូវចាត់ទុកថា បានដឹងពីអាយុ

របស់អនីតិជននោះលើកលែងតែជននោះបង្ហាញឱ្យឃើញថាខ្លួនមានការជឿជាក់ដោយសមហេតុផលថាអនីតិជននោះមានអាយុ ១៨ ឆ្នាំ ឬ ច្រើនជាង ១៨ឆ្នាំ ។

## និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់

### ការនាំយកចេញដោយមិនស្របច្បាប់នៅក្នុងច្បាប់នេះ មានន័យថា :

១. ការធ្វើឱ្យមនុស្សម្នាក់
ផ្លាស់ទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំគំរាមកំហែង បោកបញ្ឆោតបំពានអំណាច ឬ លួងលោម ។

២.ការនាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុក-ម្តាយអ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់គេ ។

**ធាតុសត្យានុម័ត**

ការធ្វើឱ្យមនុស្សផ្លាស់ទីកន្លែង(
ពីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃ)ទីកន្លែងនោះស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជន ដោយ មធ្យោបាយ : បង្ខិតបង្ខំគំរាមកំហែង បោកបញ្ឆោតបំពានអំណាច ឬ លួងលោម ។

**ធាតុអត្តនោម័ត**

មានឆន្ទៈធ្វើឱ្យមនុស្សម្នាក់
ផ្លាស់ទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំគំរាមកំហែង បោកបញ្ឆោតបំពានអំណាច ឬ លួងលោម ។

**ធាតុសត្យានុម័ត**

នាំយកចេញ( អនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ )ការគ្រប់គ្រងស្របច្បាប់ ( ឪពុក-ម្តាយអ្នកថែរក្សា ឬ អ្នកអាណាព្យាបាល )ដោយគ្មានអំណាចតាមផ្លូវ ។

**ធាតុអត្តនោម័ត**

មានឆន្ទៈនាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្រប ច្បាប់នៃឪពុក-ម្តាយអ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់គេ ។ច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់

**និយមន័យនៃអំពើលក់-ដូរមនុស្ស**

អំពើលក់-ដូរមនុស្សមានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬ ទទួលយកដោយខុសច្បាប់
នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃដោយផ្តោះប្តូរទៅនឹងរបស់មានតំលៃអ្វីមួយដោយរាប់បញ្ចូលទាំងសេវានិងមនុស្សផង ។អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្សត្រូវផ្តន្ទាទោសដូចគ្នានិងអំពើលក់-ដូរមនុស្សដោយផ្ទាល់ ។

**និយមន័យនៃអំពើពេស្យាចារនិងអំពើពេស្យាចារកុមារ**

"អំពើពេស្យាចារ" នៅក្នុងច្បាប់នេះមានន័យថា ការរួមភេទជាមួយជនណាម្នាក់ ដែលមិនកំណត់ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងទៅនឹងភេទដោយផ្តោះប្តូរនឹងវត្ថុមានតំម្លៃអ្វីមួយ ។

" អំពើពេស្យាចារកុមារ " នៅក្នុងច្បាប់នេះមានន័យថា ជាអំពើរួមភេទ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទរវាងអនីតិជនជាមួយជនដទៃដោយផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ ។

**និយមន័យនៃសញ្ចារកម្ម**

**អំពើសញ្ចារកម្ម នៅក្នុងច្បាប់នេះ មានន័យថា :**

១.ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់អ្នកដទៃ
២.ជួយ ឬ ការពារអំពើពេស្យាចាររបស់អ្នកដទៃ
៣.ជ្រើសរើសអូសទាញបណ្តុះបណ្តាលបគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ
៤.ធ្វើការគាបសង្កត់លើបគ្គលណាមួយដើម្បីឱ្យបគ្គលនោះធ្វើពេស្យាចារ ។

**និយមន័យនៃរូបភាពនិង សម្ភារៈអាសអាភាស**

រូបភាព និងសម្ភារៈអាសអាភាស រនៅក្នុងច្បាប់នេះមានន័យថា ជាសម្ភារៈអាចមើលឃើញនឹងភ្នែក ដូចជារូបថតខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលពិពណ៌នាអំពីកេរភេទ ឬ ភាពអាសអាភាសប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ ។

**និយមន័យនៃរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ**

រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ នៅក្នុងច្បាប់នេះមានន័យថា សម្ភារៈដែលអាច មើលឃើញនឹងភ្នែកដូចជារូបថតខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនិតិជនដែលធ្វើឱ្យ រំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ ។